ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខ: ១៦២ រស.និ.ណ

ថ្ងៃ...ខែ...ភទ្របទ...ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ១០ ឆ្នាំ២០២៣

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការអញ្ជើញចូលរួមពិគ្រោះថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់ឧបករណ៍ប្រកាសវិក្កយបត្រ ( Add on Spot Billing System )។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ (រួមទាំងសេចក្ដីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃសុក្រ ទី០៦ ខែតុលា ឆ្នាំ២០២៣ តទៅ រៀងរាល់ម៉ោងធ្វើការ (៨:០០នាទី ដល់១៦:៣០នាទី) ដល់ថ្ងៃអង្គារ ទី២៤ ខែតុលា ឆ្នាំ២០២៣ ត្រឹមវេលាម៉ោង ១៦:០០នាទី ក្នុងមួយច្បាប់តម្លៃ ១៦០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើពិគ្រោះថ្លៃគឺ ថ្ងៃពុធ ទី២៥ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ១៦:១៥នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យពិគ្រោះថ្លៃទាំងអស់ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការពិគ្រោះថ្លៃ ដែលមានចំនួនដូចបានកំណត់ក្នុងឯកសារពិគ្រោះថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

ជ. គណៈកម្មាធិការលទ្ធកម្ម
អនុប្រធាន

ជូ ផល្លា

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ